# របាយការណ៍សកម្មភាពការងារប្រចាំខែ មករា ឆ្នាំ ២០១៧ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

I. **ស្ថានភាពទូទៅ**

II. នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានមន្ត្រីក្របខ័ណ្ឌចំនួន ១៨ រូប (ស្រី ០៥ រូប) មន្ត្រីកម្មសិក្សា ចំនួន ០២ រូប (ស្រី ០១ រូប) និងមន្ត្រីកិច្ចសន្យាចំនួន ០១ រូប (ស្រី ០១ រូប) សរុបទាំងអស់មានចំនួន ១៩ រូប (ស្រី ០៦ រូប) ក្នុងនោះ ៖

| | |
|---|---|
| – ចំនួនមន្ត្រីរាជការ ដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ÷ | គ្មាន |
| – ចំនួនមន្ត្រីរាជការ ដែលបានទៅបំពេញបេសកកម្មនៅក្រៅប្រទេស ÷ | ០១រូប |
| ចំនួនមន្ត្រីរាជការ សម្រាកលំហែមាតុភាព ÷ | គ្មាន |
| – ចំនួនឈឺ ÷ | ០១រូប |
| – ចំនួនមន្ត្រីកិច្ចសន្យាសុំច្បាប់ទៅក្រៅប្រទេស | ០១រូប |
| – ចំនួនមន្ត្រីរាជការ ដែលបានសហប្រតិបត្តិការជាមួយអង្គការ និងកម្មវិធី ÷ | គ្មាន |

III. **លទ្ធផលការងារ**

**1. ការងារប្រជុំ និងបណ្តុះបណ្តាល**

ថ្នាក់ដឹកនាំ និងមន្ត្រី បានចូលរួមកិច្ចប្រជុំចំនួន ០២ លើក សិក្ខាសាលាចំនួន 0 លើក និងវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន ០១ លើក ÷

- **ការងារប្រជុំ**

– ប្រធាននាយកដ្ឋាន ចូលរួមប្រជុំស្តីពីការរៀបចំពិធីអបអរសាទរខួបលើកទី ៣៨ ទិវា ៧ មករា ក្រោមអធិបតីភាព **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី ០៣ នៃទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ

– ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន ០២ រូប (ស្រី ០១ រូប ) ចូលរួមប្រជុំប្រចាំសប្តាហ៍ (ស្តីពីការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងទិសដៅការងារឆ្នាំ ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ) ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣ ។

- **សិក្ខាសាលា**

– គ្មានសកម្មភាព ។

- **វគ្គបណ្តុះបណ្តាល**

– អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក ចូលរួមក្នុងវគ្គបណ្តុះបណ្តាល ភាសាអង់គ្លេស ពាក់ព័ន្ធនឹងប្រធានបទ ( Strengthening Resilience ) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៧ នៅប្រទេសណូវែលហ្សេឡង់ ។

**2. កម្មវិធីផ្សេងៗ**

– មន្ត្រីនាយកដ្ឋាន ០៤ រូប ចូលរួមកម្មវិធី**មិទ្ទីងអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៣៨ នៃទិវាជ័យជំនះ ៧ មករា** នៅថ្ងៃទី ៧ ខែមករា ឆ្នាំ ២០១៧ នៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា (ចំការមន)។